**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ២៣២៩ ព.ណ ៥២៣

ភ្នំពេញ, ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបន្តការចុះបញ្ជីពាណិជ្ជកម្មសាឡើងវិញ តាមប្រព័ន្ធស្វ័យប្រវត្តកម្ម រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូនក្រុមហ៊ុន សហគ្រាស សាខា ការិយាល័យតំណាង បុគ្រសម្ព័ន្ធ ឬទីភ្នាក់ងារទាំងឡាយដែលមិនទាន់បានចុះបញ្ជីសាឡើងវិញមេត្តាជ្រាបថា ក្រសួងពាណិជ្ជកម្មពិនិត្យឃើញថា រហូតមកទល់ពេលនេះមានក្រុមហ៊ុន សហគ្រាស សាខា ការិយាល័យតំណាង បុគ្រសម្ព័ន្ធ ឬទីភ្នាក់ងារភាគច្រើនបានធ្វើការចុះបញ្ជីពាណិជ្ជកម្មសាឡើងវិញតាមកាលកំណត់របស់ក្រសួងពាណិជ្ជកម្ម ដូចក្នុងប្រកាសរបស់ក្រសួងពាណិជ្ជកម្ម លេខ ៣០០ ពណ.ចបព.ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការចុះបញ្ជីពាណិជ្ជកម្មសាឡើងវិញក្នុងប្រព័ន្ធស្វ័យប្រវត្តកម្ម និងសេចក្តីជូនដំណឹងនៃការពន្យារពេលរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦។

ដើម្បីផ្តល់ឱកាសជូនក្រុមហ៊ុន សហគ្រាស សាខា ការិយាល័យតំណាង បុត្រសម្ព័ន្ធ ឬទីភ្នាក់ងារទាំងឡាយដែលមិនទាន់បានចុះបញ្ជីពាណិជ្ជកម្មសាឡើងវិញ ក្រសួងពាណិជ្ជកម្មសម្រេចបន្តការចុះបញ្ជីពាណិជ្ជកម្មសាឡើងវិញតាមប្រព័ន្ធស្វ័យប្រវត្តកម្ម **រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧។** ប៉ុន្តែក្រុមហ៊ុន សាខា ការិយាល័យតំណាង បុត្រសម្ព័ន្ធ ឬទីភ្នាក់ងារទាំងឡាយ ត្រូវភ្ជាប់ប្រតិវេទន៍អំពីស្ថានភាពសហគ្រាសពាណិជ្ជកម្មប្រចាំឆ្នាំ២០១៥។

ក្នុងករណីក្រុមហ៊ុន សាខា ការិយាល័យតំណាង បុត្រសម្ព័ន្ធ ឬទីភ្នាក់ងារ ដែលមិនមានប្រតិវេទន៍អំពីស្ថានភាពសហគ្រាសពាណិជ្ជកម្មប្រចាំឆ្នាំ២០១៥ ត្រូវបង់កម្រៃសេវាតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ និងការពិន័យចំពោះការមិនតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ នៅក្រសួងពាណិជ្ជកម្ម ដូចមានកំណត់ក្នុងប្រកាសរួមលេខ ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០១៤ រវាងក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀតជាធរមាន។

ក្រសួងពាណិជ្ជកម្មសង្ឃឹមយ៉ាងមុតមាំថា ក្រុមហ៊ុន សហគ្រាស សាខា ការិយាល័យតំណាង បុត្រសម្ព័ន្ធ ឬទីភ្នាក់ងារទាំងអស់នឹងរួសរាន់ចុះបញ្ជីសាឡើងវិញតាមប្រព័ន្ធស្វ័យប្រវត្តកម្ម តាមកាលកំណត់ជាក់ជាមិនខាន។

សេចក្តីជូនដំណឹងនេះនឹងត្រូវអនុវត្តចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងពាណិជ្ជកម្ម

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
*Phone/Facsimile: (855)-23 866 469*